# កសាងសមត្ថភាពបញ្ញវន្ត ៖ កម្មវិធីស្រាវជ្រាវក្រោមការឧបត្ថម្ភរបស់មូលនិធិ រ៉ុកហ្វេល្លឺរ

*ដោយ ហ្វ្រង់ស្វា តាំងទុយរីយេ៉*

មូលនិធិ រ៉ុកហ្វេល្លឺរ បានឧបត្ថម្ភជាទឹកប្រាក់ដល់មជ្ឈ-មណ្ឌលខេមរសិក្សា សម្រាប់អនុវត្តកម្មវិធីស្រាវជ្រាវមួយ ដែលមាន ៣ ផ្នែក ក្នុងរយៈពេល ៣ ឆ្នាំ ក្រោមចំណងជើង “ការច្នៃប្រឌិត និង វប្បធម៌” យោងតាមអនុសាសន៍នៃសិក្ខាសាលា “លក្ខណៈការអនុវត្ត និង អនាគតនៃខេមរសិក្សា” ដែល ម.ខ.ស. រៀបចំកាលពីខែមករា ឆ្នាំ ២០០១ កន្លងមកនេះ ។

អ្នកចូលរួមក្នុងសិក្ខាសាលារបស់ ម.ខ.ស. នាពេលនោះបានព្រមព្រៀងគ្នាជ្រើសរើសយកបុរាណវិទ្យាសម័យមុនអង្គរ នរសង្គមវិទ្យា និងស្ថាបត្យកម្មប្រពៃណី ក្នុងចំណោមវិទ្យាទាំងឡាយ ដែលបានស្នើឡើង ដោយគិតថាវិទ្យាទាំង ៣ នេះ មានសារៈសំខាន់ខ្ពស់ ងាយស្រួលក្នុងការអនុវត្ត ហើយនិងសមស្របជាមួយធនធានមនុស្សផង ។

កម្មវិធីនរវិទ្យា បានចាប់ផ្តើមកាលពីខែ តុលា ឆ្នាំ ២០០១ ហើយបន្ទាប់មកទៀត មានកម្មវិធីស្ថាបត្យកម្មប្រពៃណីដែលបានចាប់ផ្តើមនៅខែធ្នូនេះ ។ ម.ខ.ស បានរៀបចំការិយាល័យមួយនៅក្រុងភ្នំពេញដើម្បីសម្រួលឲ្យអ្នកស្រាវជ្រាវ អាចធ្វើការនិងមានទំនាក់ទំនងគ្នាក្នុងបរិយាកាស ដ៏ត្រជាក់ល្អកល្អឺន ។

កម្មវិធីបុរាណវិទ្យាសម័យមុនអង្គរ នឹងចាប់ផ្តើមដំណើរការនៅខែមីនា ឆ្នាំ ២០០២ ត្រូវនឹងពេលដែល ម.ខ.ស. រៀបចំសិក្ខាសាលាមួយ នៅខេត្តសៀមរាប ។

កម្មវិធីនរវិទ្យា មានការវិវត្តក្រោមកិច្ចសហប្រតិបត្តិការជាមួយបណ្ឌិត វិល្លៀម ខូល្លិន្ស ដែលអញ្ជើញមកពីមជ្ឈមណ្ឌលសិក្សាអាស៊ីអាគ្នេយ៍ នៃសាកលវិទ្យាល័យខាលីហ្វរញ៉ៀ បឺរខ្លី និង លោក គឹម សេតារា ជាអ្នកនរវិទ្យាវប្បធម៌ ។ កម្មវិធីនេះ ទាក់ទងទៅនឹងវិស័យអប់រំជាន់ខ្ពស់នៅកម្ពុជា ហើយនិងយកចិត្តទុកដាក់ទៅលើដេប៉ាតឺម៉ង់ចំនួន ៥ (នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកល-វិទ្យាល័យភូមិន្ទភ្នំពេញ និងសាលាកសិកម្មព្រែកលាប) ក្នុងកម្មវិធីទាក់ទងទៅនឹងល័ក្ខសូត្ររបស់និស្សិតនៃវិទ្យាស្ថានទាំងនេះ ការប្រព្រឹត្តយ៉ាងនេះ នឹងធ្វើឲ្យយើងអាចយល់ដឹងនូវដំណើរការសិក្សា និងសេចក្តីត្រូវការរបស់និស្សិតទាំងនេះ ។ ទំនាក់ទំនងនិងការសេពគប់គ្នារវាង និស្សិត ក្នុងដេប៉ាតឺម៉ង់ទាំង ៥ នេះ ក៏នឹងយកធ្វើជាប្រធានបទសិក្សាទៀតផង ។

ម.ខ.ស. ទទួលនិស្សិតដែលបានបញ្ចប់ការសិក្សាចំនួន ៣ នាក់ គឺ កញ្ញា ហេង ឈុងអឿន លោក រុន សម្បត្តិ ចេញមកពី មហា-វិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចត្រសិល្បៈ និង កញ្ញា ហាក់ ស៊ីភីរ័តន៍ ពីដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា នៃ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីចូលមកធ្វើការក្នុងឋានៈជាអ្នកជំនួយការស្រាវជ្រាវ និងដឹកនាំកម្មវិធីស្រាវជ្រាវដែលនៅក្រោមការត្រួតពិនិត្យរបស់លោកបណ្ឌិត ខូល្លិន្ស និង លោក គឹម សេតារា ។

រីឯកម្មវិធីស្ថាបត្យកម្មប្រពៃណី ស្ថិតនៅក្រោមការដឹកនាំរបស់បណ្ឌិតបេងហុងសុជាតិខេមរ៉ូមកពីរាជបណ្ឌិតសភាកម្ពុជា និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ លោកស្ថាបត្យករ ហុក សុកុល មកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង ខ្ញុំបាទផ្ទាល់ ។ កម្មវិធីនេះ មានវត្ថុបំណង ២ គឺ ៖ ក-អភិវឌ្ឍទិន្នន័យនៃ ជី.អែ.អេស ១ ដែលធ្វើបញ្ជីរចនាសម្ព័ន្ធស្ថាបត្យកម្មប្រពៃណី (សំខាន់គឺ វត្តអារាម និង ផ្ទះ) នៅខេត្តបាត់ដំបង កំពង់ចាម និង ក្រចេះ និង ខ-សិក្សាអំពីទីក្រុងខ្នាតមធ្យមរបស់ខ្មែរ ជាឱកាសដ៏ល្អមួយសម្រាប់ឲ្យយើងធ្វើការជាមួយអង្គការផ្សេង ។ ដូចជា ជី.ធី.ហ្សែត (GTZ) ទីភ្នាក់ងារអាល្លឺម៉ង់ សាកលវិទ្យាល័យហាម្បុគ៌ (អាល្លឺម៉ង់) និង វិទ្យាស្ថានអប់រំផ្សេង ។ ទៀត ដែលអាចធ្វើទៅបាន ។

និស្សិត២នាក់ដែលកំពុងរៀនឆ្នាំចុងបញ្ចប់ក្នុងមហាវិទ្យា-ល័យស្ថាបត្យកម្ម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គឺ កញ្ញា គង់ បញ្ញា និង លោក អ៊ុនផេង ពុទ្ធវិសាល បានទទួលតួនាទីជាអ្នកជំនួយការស្រាវជ្រាវ ។ ពេលដែលដំណើរសិក្សាស្រាវជ្រាវចាប់ផ្តើម និស្សិតកំពុងរៀន ឬ ដែលបានបញ្ចប់ការសិក្សា ជាច្រើនរូបទៀតអាចនឹងចូលមកធ្វើការបាន ។

ដំណើរការនៃកម្មវិធីបុរាណវិទ្យាសម័យមុនអង្គរ នឹងធ្វើទៅក្រោមការដឹកនាំរបស់លោកបណ្ឌិត ចន មិកស៊ិច ជាសាស្ត្រាចារ្យសហការីនៃកម្មវិធីសិក្សាអាស៊ីអាគ្នេយ៍ របស់សាកលវិទ្យាល័យជាតិសិង្ហបុរី ។ កម្មវិធីនេះ ក៏នឹងទទួលជំនួយពីសាកលវិទ្យាល័យហាវ៉ៃផងដែរ សម្រាប់ការស្រាវជ្រាវដល់ទីកន្លែង ។

កម្មវិធីនេះ នឹងមានការជួយជ្រោមជ្រែងពីលោកបណ្ឌិត វិល្លៀម សោធរើរធ៍ ជាបុរាណវិទូ និងជាសមាជិកនៃ ម.ខ.ស. និង បណ្ឌិត ខែល៍ ឡាទីនីស ជានរវិទូ មកពីសាកលវិទ្យាល័យជាតិ សិង្ហបុរី ។

ទន្ទឹមនឹងគម្រោងនេះដែរ លោកបណ្ឌិត ចន មិកស៊ិច និង ខែល៍ ឡាទីនីស ក៏បានទទួលបន្ទុកវគ្គបណ្តុះបណ្តាលអំពីការចាត់ការធនធានវប្បធម៌ ដែលជាកម្មវិធីមួយឧបត្ថម្ភដោយមូលនិធិ សេន្យបេរី និងរៀបចំដោយ ម.ខ.ស. នៅក្រុងភ្នំពេញ ។ ការប្រគល់កម្មវិធី ២ នេះ ទៅក្រោមការទទួលខុសត្រូវរបស់បណ្ឌិតទាំង ២ រូប នេះ នឹងជួយផ្តល់ឲ្យការបណ្តុះបណ្តាលមានគុណភាពដ៏ល្អក្រៃលែង ។

## វិធីសាស្ត្រការងារ

កម្មវិធី “កសាងសមត្ថភាពបញ្ញវន្ត” (Building Intellectual Capacity) របស់មូលនិធិ រ៉ុកហ្វេល្លឺរ គឺជាភាពចាប់ផ្តើមនៃដំណាក់កាលប្រតិបត្តិការរបស់ ម.ខ.ស. ។ គោលការណ៍ណែនាំ ការអភិវឌ្ឍ

និងការចាត់ចែងកម្មវិធី ជាកត្តាសំខាន់បំផុតសម្រាប់ដំណាក់កាលប្រតិបត្តិការនេះ ។

កម្មវិធីនេះ ជាឱកាសមួយសម្រាប់ពង្រីកវិធីសាស្ត្រការងារនៅកម្ពុជាដែលប្រកបដោយនិច្ឆ័យសរុប និង និច្ឆ័យសេវាសាធារណៈ ព្រមទាំងបង្កើតទស្សនៈប្រមើលអនាគត ដែលអាចមានលក្ខណៈផ្សេងពីការដោះស្រាយរបៀបបស្ចិមប្រទេស ។

គេនឹងបង្កើតឲ្យមានសភាពថ្មី។ក្នុងសហការរវាងវិទ្យាស្ថាននានា និង បុគ្គលឯកជនដែលមានអត្ថប្រយោជន៍ដូចគ្នា ។ សម្រាប់ផ្នែកស្ថាបត្យកម្មប្រពៃណី និង ផ្នែកបុរាណវិទ្យាសម័យមុនអង្គរ នឹងមានការធ្វើសិក្ខាសាលាអំពីចំណុចដែលមានលក្ខណៈជាឯកទេស ហើយដែលប្រមូលផ្តុំអ្នកជំនាញ វិទ្យាស្ថាន និង បុគ្គលឯកជនទាំងឡាយណាដែលចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យសិក្សាស្រាវជ្រាវទាំងនេះ ។ គេនឹងចូលរួមធ្វើការពិចារណា និងធ្វើការស្ទង់ប៉ាន់មើលការស្រាវជ្រាវ ព្រមទាំងឯកសារនានាដែលមានស្រាប់ ហើយគេក៏អាចជួយសម្រួលដំណើការស្រាវជ្រាវទៅអនាគតរបស់ពួកគេ ឲ្យកាន់តែប្រសើរឡើងទៅទៀត ។

កម្មវិធីរ៉ុកឺហ្វេល្ល័រ របស់ ម.ខ.ស ក៏នឹងជំរុញឲ្យមានការផ្តោះប្តូរសេវារវាងកម្មវិធីផ្សេង ។ ដែលគ្រប់គ្រងដោយ ម.ខ.ស ឬដោយអង្គរការដទៃទៀតផងដែរ ។ ឧទាហរណ៍ដូចជា ក្នុងបច្ចុប្បន្ននេះ អ្នកជំនួយការស្រាវជ្រាវទាំង ៣ នាក់ ដែលមានវិស័យសិក្សាពាក់ព័ន្ធទៅនឹងការសេពគប់ទាក់ទងគ្នារវាងនិស្សិសសាកលវិទ្យា-ល័យ អ្នកជំនួយការស្រាវជ្រាវទាំងនេះ ជួយធ្វើការបណ្ឌិត ខៃលី ឡាទីនីស ក្នុងវគ្គបណ្តុះបណ្តាលការចាត់ការធនធានវប្បធម៌ ដែលកំពុងបង្រៀននៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។ វគ្គបណ្តុះបណ្តាលនេះប្រមូលផ្តុំនិស្សិតមកពីដេប៉ាតឺម៉ង់ និង សាកលវិទ្យាល័យផ្សេង ។ គ្នា ហើយនិងផ្តល់ជូននូវឱកាសដ៏ល្អសម្រាប់ឲ្យអ្នកជំនួយការស្រាវជ្រាវធ្វើការសម្ភាសពួកនិស្សិត ។ បទសម្ភាសន៏ទាំងនេះដែលជាភាគសំខាន់មួយក្នុងកម្មវិធីស្រាវជ្រាវរបស់អ្នកទាំង ៣ នេះ នឹងជួយចម្រើនទំហំនៃការស្ទង់មតិ ដែលអ្នកទាំង ៣ ធ្វើនៅក្នុងដេប៉ាតឺ-ម៉ង់ទាំង ៥ ។

ជាថ្នូរ អ្នកជំនួយការស្រាវជ្រាវអាចជួយនិស្សិតនៃគម្រោងសេនឲ្យបេរី ឲ្យយល់អំពីសេចក្តីគិត និង គំនិតដែលទាក់ទងទៅនឹងការចាត់ការធនធានវប្បធម៌ ។ ពិតមែនហើយ ការចូលរួមរបស់អ្នកជំនួយការស្រាវជ្រាវទាំង ៣ នាក់ នឹងមានប្រយោជន៏សម្រាប់ការជជែកពិភាក្សាក្នុងក្រុម ពីព្រោះនិស្សិតទាំងឡាយ ត្រូវការសាងគម្រោងស្រាវជ្រាវរបស់ខ្លួន ឲ្យសមស្របទៅតាមបែបបទ ។

ចំពោះកម្មវិធីស្រាវជ្រាវស្ថាបត្យកម្មប្រពៃណីវិញ ការផ្តោះប្តូរសេវា នឹងត្រូវបានពង្រីកទៅជាមួយនឹង ជី.ធី.ហ្សែត ក្នុងការសិក្សាអំពីទីក្រុងខ្នាតមធ្យម ។ ក្រុមស្រាវជ្រាវដែលបានឧបត្ថម្ភពីមូលនិធិ រ៉ុកឺហ្វេល្ល័រ នឹងទទួលបន្ទុកកិច្ចការស្រាវជ្រាវអំពីប្រវត្តិ និងបូរីអភិវឌ្ឍន៏ នៃទីក្រុងដែលបានជ្រើសរើស ហើយផលនៃការសិក្សាស្រាវជ្រាវទាំងនេះ នឹងផ្តល់ឲ្យក្រុម ជី.ធី.ហ្សែត ដើម្បីឲ្យពួកគេអាចយកមកប្រើជាគ្រឹះ សម្រាប់គម្រោងអភិវឌ្ឍទីក្រុងរបស់ខ្លួន ដែលនឹងបង្ហាញទៅអាជ្ញាធរមូលដ្ឋាន ។ ជាថ្នូរ ក្រុម ជី.ធី.ហ្សែត នឹងផ្តល់ជំនួយដល់ក្រុមស្រាវជ្រាវរបស់កម្មវិធីស្ថាបត្យកម្មប្រពៃណី ដើម្បីជួយធ្វើបញ្ជីសារពើភ័ណ្ឌនៃរចនាសម្ព័ន្ធក្នុងស្រុកដោយប្រើរូបថតដែលថតពីលើអាកាស ។

ក្នុងការកសាងជាថ្មីនូវបរិបទនៃការស្រាវជ្រាវ ក្រុមកម្មវិធីរ៉ុកឺហ្វេល្ល័រ នឹងធ្វើឲ្យសាស្ត្រាចារ្យខ្មែរ និងបរទេសធ្វើសហការគ្នា ក្នុងគោលបំណងចង់ផ្តល់នូវទស្សនវិស័យថ្មីមួយលើប្រទេសកម្ពុជាដើម្បីយកទៅប្រើនៅក្នុងវិស័យស្រាវជ្រាវ ។

ការបង្កើតក្រុមដែលមានទាំងអ្នកប្រាជ្ញខ្មែរនិងបរទេស នឹងនាំមកនូវឱកាសដ៏ប្រពៃ សម្រាប់បណ្តុះបណ្តាលយុវជនដែលរៀនចប់មហាវិទ្យាល័យ អំពីវិធីសាស្ត្រស្រាវជ្រាវ ព្រោះថា វគ្គសិក្សាដែលសាកលវិទ្យាល័យទាំងឡាយនៅប្រទេសកម្ពុជាធ្វើឡើង មានបង្រៀនតិចតួចអំពីរបៀបធ្វើការស្រាវជ្រាវ ។ ដូចមានអធិប្បាយនៅក្នុងអត្ថ-ន័យនៃចំណងជើងថា (Building Intellectual Capacity) “កសាងសមត្ថភាពបញ្ញវន្ត” គឺថា ការអប់រំនូវវិធីសាស្ត្រស្រាវជ្រាវ និង ទំហំនៃការស្រាវជ្រាវ ក៏មានសារៈសំខាន់ដូចគ្នាដែរ ។ ដោយសារកម្មវិធីនេះ មានដំណើរការគម្រប់ ៣ ឆ្នាំ យុវជនដែលចេញពីមហាវិទ្យាល័យទាំងនេះ នឹងមានបទពិសោធន៏ការងារដ៏យូរអង្វែងជាលើកដំបូង ។

## លទ្ធផលនៃកម្មវិធី

តាមរយៈការផ្សព្វផ្សាយវិធីសាស្ត្រការងារដូចដែលបរិយាយក្នុងអត្ថបទនេះ កម្មវិធីស្រាវជ្រាវរបស់មូលនិធិ រ៉ុកឺហ្វេល្ល័រ មានគោលបំណងបង្កើតទម្លាប់ក្នុងកម្មវិធីចាត់ចែងសម្រាប់គម្រោងការថ្មី ។ របស់ ម.ខ.ស ទៅអនាគត (ដូចជាបង្កើតក្រុមចម្រុះទៅដោយជនជាតិខ្មែរនិងជនជាតិបរទេស ការបណ្តុះបណ្តាលនិស្សិតដែលទើបនឹងរៀនចប់ អំពីវិធីសាស្ត្រស្រាវជ្រាវ ការស្ម័គ្រចិត្តបរិច្ចាកពេលវេលារបស់វិជ្ជាករបរទេស ឬ អត្ថបទបោះពុម្ពផ្សាយរួម ជាដើម) ។

អាហារូបករណ៏របស់មូលនិធិ រ៉ុកឺហ្វេល្ល័រ ជួយបង្កើនថាមពលសម្រាប់ការស្រាវជ្រាវ ដែលជាកត្តានាំឲ្យ ម.ខ.ស. ដើរតួឯក នៅលើឆាកនៃការសិក្សាស្រាវជ្រាវនៅប្រទេសកម្ពុជា តាមរយៈការរៀបចំរោងជាងនិងសិក្ខាសាលានាពេលចាប់ផ្តើមកម្មវិធីស្រាវជ្រាវ និងបញ្ចប់កម្មវិធីស្រាវជ្រាវ ព្រមទាំងសហប្រតិបត្តិការ រវាងវិទ្យាស្ថានអប់រំផ្សេង។ ។

ទីបញ្ចប់ សកម្មភាពដ៏សំខាន់ជាងគេរបស់ ម.ខ.ស. គឺ ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវសម្រាប់កម្មវិធីទាំង ៣ នឹងធ្វើឡើងតាមការបោះពុម្ពផ្សាយ ជាពិសេសតាមរយៈព្រឹត្តិប័ត្រ *សិក្សាចក្រ* របស់ ម.ខ.ស និងការតាំងពិព័រណ៏ ។ ការបោះពុម្ពផ្សាយនូវការស្រាវជ្រាវបុរាណវិទ្យាសម័យមុនអង្គរ មុខជានឹងទាក់ទាញតែចំណាប់អារម្មណ៏របស់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងនិស្សិតក្នុងវិស័យស្ថាបត្យកម្មប៉ុណ្ណោះ ប៉ុន្តែលទ្ធផលនៃកម្មវិធី ២ ដទៃទៀតវិញ ក៏គង់តែនឹងផ្តល់ឱកាសជំនុំជាសាធារណៈ ដោយអាងទៅលើទស្សនវិស័យថ្មីថ្មោងមួយអំពីបញ្ហាដែលមានផលសំខាន់បំផុតក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ គឺបញ្ហាពង្រឹងវិស័យអប់រំជាន់ខ្ពស់ឲ្យកាន់តែល្អឡើង និងបញ្ហាសំណង់បុរាណខ្មែរ ដែលកំពុងរលាយសាបសូន្យយ៉ាងឆាប់រហ័ស ៕